ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ: ......១០៩/១៦......អ.ប.ក

# របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមិថុនា និងទិសដៅខែ កក្កដា ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៦ )

## I.ស្ថានភាពទូទៅ

នៅក្នុងខែមិថុនា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានបំពេញតួនាទីតាមមុខងាររបស់ខ្លួនដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ដោយមានកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលជាដៃគូជាតិនិងអន្តរជាតិ។

អំពីសភាពការណ៍បទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្អែកតាមរបាយការណ៍ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ បានរកឃើញបទល្មើសជាច្រើនករណី តាមទម្រង់ផ្សេងៗដូចជាការធ្វើអាជីវកម្មផ្លូវភេទ សញ្ចារកម្ម និងទេសន្តរប្រវេសន៍ស្វែងរកការងារ ការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ក្នុងចំណោមជនទេសន្តរប្រវេសន៍ ដែលកំពុងនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ ត្រូវបានរងគ្រោះជាបន្តបន្ទាប់ និងត្រូវបានបញ្ជូនមកកម្ពុជាវិញ ហើយមួយចំនួនបានត្រឡប់មកផ្ទះវិញដោយខ្លួនឯង និងខ្លះទៀតបាត់ដំណឹង ។ កត្តាទាំងអស់នេះ ជាបញ្ហាប្រឈម ដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ត្រូវរួមសហការជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិក និង អង្គភាពដែលពាក់ព័ន្ធ ត្រូវព្យាយាមបង្ការទប់ស្កាត់ និងដោះស្រាយបញ្ហារួមគ្នា ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានា សុំឲ្យមានការស្រាវជ្រាវស៊ើបអង្កេតបទល្មើស និងសិក្សាពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបំពេញតួនាទី និងភារកិច្ចយ៉ាងមមាញឹក ខិតខំប្រឹងប្រែងបន្តអនុវត្តយុទ្ធវិធី តាមផែនការសកម្មភាពជាតិ ឆ្នាំ២០១៤-២០១៨ ដើម្បីបន្តសកម្មភាពក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំរុញការដឹកនាំ ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការដាក់ទណ្ឌកម្ម លើជនល្មើស ។

របាយការណ៍ខាងក្រោម ជាទិន្នន័យដែលទទួលបានពីក្រុមការងារអនុវត្តន៍ច្បាប់ចំនួន០១ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងរាជធានី/ខេត្ត ចំនួន២២ច្បាប់ គឺ (រាជធានីភ្នំពេញ ,ខេត្ត កោះកុង ,ព្រះសីហនុ ,កែប តាកែវ ,កំពង់ឆ្នាំង ,កណ្តាល , ស្វាយរៀង ,ព្រៃវែង ,ពោធិ៍សាត់ ,ប៉ៃលិន ,បាត់ដំបង , ឧត្តរមានជ័យ ,បន្ទាយមានជ័យ ព្រះវិហារ , សៀមរាប ,កំពង់ធំ, ក្រចេះ ,ស្ទឹងត្រែង ,រតនគិរី ,មណ្ឌលគិរី និងខេត្តត្បូងឃ្មុំ) និងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលទទួលបានលទ្ធផល ដូចខាងក្រោម ៖

## II.លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅក្នុងខែមិថុនា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅការកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការ រវាងបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

### ក. ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

**១. ការងារបង្ការ-ទប់ស្កាត់:**

**១.១.ការផ្សព្វផ្សាយ អប់រំ**

នៅក្នុងខែមិថុនា ឆ្នាំ២០១៦នេះ ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ចបានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ទៅតាមគោលដៅចំនួន១,៦៦១លើក បើប្រៀបធៀបខែមុនមានចំនួន១,៤៤៦លើក មានការកើនឡើងចំនួន២១៥លើក ស្មើនឹង១៤,៨៦% និងមានមនុស្សចូលរួមសរុបចំនួន២៤៨,០៨០នាក់ បើប្រៀបធៀបខែមុនមានចំនួន២១៨,៧០៤នាក់ មានការកើនឡើងចំនួន២៩,៣៧៦នាក់ ស្មើនឹង១៣,៤៣% ក្នុងនោះស្ត្រីមានចំនួន១០៥,៣១២នាក់។ (**ឧបសម្ព័ន្ធទី១**)

**១.២.ការងារបង្ការ-ទប់ស្កាត់**

យោងលើលទ្ធផលសម្រេចបាន លើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលនាយកដ្ឋានជំនាញសមត្ថកិច្ចកងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធទទួលបានលទ្ធផលសរុបៈ

- ចំនួន**១៤**លើកបើប្រៀបធៀបខែមុនមានចំនួន០៦លើក កើនចំនួន០៨នាក់ មានមនុស្សចំនួន**១៤៦**នាក់បើប្រៀបធៀបខែមុនមានចំនួន៤៩នាក់បើប្រៀបធៀបខែមុនមានការកើនឡើងចំនួន**៩៧**នាក់ស្មើនឹង**១៩៧,៩៥%** ស្ត្រីចំនួន**១១៣**នាក់
- ចំនួន១,០៦៥**គោលដៅ** បើប្រៀបធៀបខែមុនមានចំនួនគោលដៅ មានមនុស្សចំនួន២,៥៤៧នាក់ បើប្រៀបធៀបខែមុនមានចំនួន២,៨៧៩នាក់មានការថយចុះចំនួន៣៣២ ស្មើនឹង១១,៥៣% ស្ត្រីចំនួន១,៨៦៨នាក់ ។
  - ស្នងការដ្ឋាននគរបាល**ខេត្តតាកែវ ,កណ្តាល ,កោះកុង ,ក្រចេះ , និងខេត្តកំពង់ឆ្នាំង** បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យា ហាមឃាត់ ការប្រព្រឹត្តអំពើសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការ បង្រ្កាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា, ខារ៉ាអូខេ បានចំនួន៣៥០គោលដៅ និងមានមនុស្សចំនួន១,១១៥នាក់ (ស្រីចំនួន៨២១នាក់) ។
  - បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ទាំង២៥ រាជធានី-ខេត្ត មានចំនួន៧១គោលដៅ ក្នុងនោះអំពើជួញដូរមនុស្ស ចំនួន០៥គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ ។
  - ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល**ខេត្តពោធិ៍សាត់** បានសហការជាមួយអង្គការ(PVT ,AARR ,BEDAS ,DCO ,COCD ,KNKS ,លីកាដូ ,ស្ថានយុត្តិធម៌អន្តរជាតិ ,វឌ្ឍនភាព)និងសមាគមន៍ការពារសិទ្ធិមនុស្សអាដហុក បានចុះល្បាតត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល ,ហាងម៉ាស្សា,ហាងលក់ជួលឌីស, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ ភោជនីយដ្ឋាននិងនារីបម្រើក្រុមហ៊ុនស្រាបៀរ សរុបចំនួន**១៩៥**កន្លែងស្មើនឹង**១៩៥**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន៨៣៣នាក់ ស្រីចំនួន**៥៩១**នាក់ ។
- ○ **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង**
- បានផ្សព្វផ្សាយតាមវិទ្យុប្រជាជន FM ១០០.២៥MHz ក្នុងប្រធានបទ ស្តីពី "ការលើកកម្ពស់ ការយល់ដឹងអំពីសិទ្ធិ និងពលកម្មកុមារ ដល់យុវជន" តាមប្រកាសលេខ៣០៩ ពីល័ក្ខខ័ណ្ឌការងារក្នុងសិប្បកម្មឡឥដ្ឋបានចំនួន០៣លើក ។

○ស្នងការដ្ឋាននគរបាល**ខេត្តសៀមរាប**

-ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេសរុបចំនួន**៩៣**កន្លែងស្មើនឹង**៩៣**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមផ្សព្វផ្សាយ ស្តីពីច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស តាមវិទ្យុបានចំនួន០៤លើក និងបានចុះល្បាត ពេលយប់នៅតាមផ្សាររាត្រី មាត់ស្ទឹងតាមសួនច្បារមុខសណ្ឋាគារ (Grand Hotel )។

ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល**ខេត្តស្ទឹងត្រែង** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន**១០២**កន្លែងស្មើនឹង**១០២**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

○ស្នងការដ្ឋាននគរបាល**ខេត្តមណ្ឌលគិរី** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល ,ហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន**៧៩**កន្លែងស្មើនឹង**៧៩**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើចំនួន៤៤៩នាក់ ស្រីចំនួន២៩៨នាក់ ។

○ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល**ខេត្តកែប** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល,ហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន**១៤**កន្លែង ស្មើនឹង**១៤**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន**១៥០**នាក់ ស្រីចំនួន**១២៦**នាក់ ។

○ស្នងការដ្ឋាននគរបាល**ខេត្តតាកែវ** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល ,ហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន**២២៥**កន្លែងស្មើនឹង**២២៥**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

○ស្នងការដ្ឋាននគរបាល**ខេត្តកំពង់ឆ្នាំង** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់ ហាងខារ៉ាអូខេ នៅភូមិទួលក្រឡាញ់ចំនួន០១កន្លែងស្មើនឹង០១គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានស្ត្រីបម្រើនៅក្នុងហាងចំនួន**៣២**នាក់។

○ស្នងការដ្ឋាននគរបាល**ខេត្តព្រៃវែង**

-បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល ,ហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន០៦កន្លែងស្មើនឹង០៦គោលដៅ ដើម្បីចូលរួមសហការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-បានចូលរួមជាវាគ្មិនក្នុងវេទិកា ស្តីពីសុវត្ថិភាពចំណាកស្រុក និងការងារ រយៈពេល១ថ្ងៃ នៅសាលាឃុំសេនារាជឧត្តម ស្រុកព្រះស្តេច ដែលមានអ្នកចូលរួមចំនួន៩៣នាក់ ស្រីចំនួន៦៩នាក់ ។

-ស្នងការដ្ឋាននគរបាល**ខេត្តស្វាយរៀង** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់ ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន០៦លើក ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន**៥៣**នាក់ ស្រីចំនួន៤៤នាក់ ។

## ២. ការងារការពារ ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍

### ២.១ ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម សរុបបានចំនួន២៨នាក់ បើប្រៀបធៀបខែមុនមានចំនួន១២៩នាក់ មានការថយចុះចំនួន១០១នាក់ ស្មើនឹង៧៨,២៩% ក្នុងនោះស្ត្រីមានចំនួន០៥នាក់ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ

-បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០៥នាក់ ដើម្បីធ្វើការស្រាវជ្រាវរកគ្រួសារមុនពេលធ្វើមាតុភូមិនិវត្តន៍មកប្រទេសកំណើតវិញ ។

+ក្រុមការងាររបស់លេខាធិការដ្ឋាន បានសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកំពង់ធំ៖

-បានចុះជួយជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ ដើម្បីទទួលសេវាថែទាំសុខភាព មានចំនួន០៤នាក់(ស្រី) (អនីតិជនចំនួន០១នាក់ និងនីតិជន០៣នាក់) ដែលយកបានពីទីតាំងខារ៉ាអូខេ ស្ថិតនៅក្នុងស្រុកស្ទោង ព្រមទាំងបានធ្វើការអប់រំណែនាំ និងឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ។

-បានទទួលពលការិនីចំនួន០១នាក់ធ្វើការនៅក្រៅប្រទេស រស់នៅក្នុងភូមិបាល័ង្គខាងលិច ឃុំលេខ១ ទីរួមខេត្តកំពង់ធំ ដែលមកតាមរយៈក្រសួងការបរទេសបញ្ជូនមកក្រសួងសង្គមកិច្ចរាជធានីភ្នំពេញ និងត្រូវបានអង្គការតេនះយកមកបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឲ្យគាត់មានមុខរបរ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តសៀមរាប បានចុះបាន់ប្រមាណគ្រួសាររងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០៤នាក់ ដែលបានស្នាក់នៅមណ្ឌលអង្គការព្រាបស ដើម្បីទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តព្រៃវែង បានសហការជាមួយគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានវត្តមានលោកជំទាវ ជូ ប៊ុនអេង ជាអនុប្រធានអចិន្ត្រៃយ៍ ចូលរួមទទួលពលករខុសច្បាប់មកពីប្រទេសឥណ្ឌូនេស៊ី និងបានសំណេះសំណាលជាមួយពលករចំនួន១៩នាក់ ។

### ២.២ សមាហរណកម្ម និងមាតុភូមិនិវត្តន៍ៈ ក្នុងខែមិថុនា ឆ្នាំ ២០១៦

ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត បានទទួល និងសម្ភាសពលករទេសន្តរប្រវេសន៍ ដែលអាជ្ញាធរម៉ាឡេស៊ីបញ្ជូនមក និងអាជ្ញាធរវៀតណាមបញ្ជូនមកវិញ ក្នុងខែមិថុនា ឆ្នាំ២០១៦ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។ (**ឧបសម្ព័ន្ធទី៤**)

### ២.៣ ការងារទទួលពលករខ្មែរពីអាជ្ញាធរបរទេសៈ

ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ និងខេត្តស្វាយរៀង បានទទួលការសម្ភាសពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារអន្តរជាតិបាវិត មានចំនួន៣,០៤៣នាក់(ស្រីចំនួន១,០១៤នាក់) អនីតិជនចំនួន២៧៣នាក់ (ស្រីចំនួន១០៨នាក់) ។

- ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យមានចំនួន៣,០៣៨នាក់ (ស្រីមានចំនួន១,០១១នាក់) អនីតិជនចំនួន២៦៨នាក់ (ស្រីចំនួន១០៥នាក់) ។
- ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង មានចំនួន០៥នាក់ (ស្រីមានចំនួន០៣នាក់) អនីតិជនចំនួន០៥នាក់ (ស្រីចំនួន០៣នាក់) ។

-មានប្រជាពលរដ្ឋខ្មែរចំនួន១៤៧នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជាវិញ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

**៣. ការងារអនុវត្តច្បាប់**

-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស

នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដាន ស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន០៣ករណី/០៣ករណី(បើប្រៀបធៀបខែមុនស្មើគ្នា)ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន០៣នាក់(ស្រីចំនួន០២នាក់) សង្គ្រោះជនរងគ្រោះបានចំនួន០៦នាក់ ក្នុងនោះអាយុពី១៥-១៧ឆ្នាំចំនួន០២នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន០៤នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៦នាក់ ។

➢ **អំពើជួញដូរមនុស្ស:**

សរុបចំនួន០១ករណី/០ករណី ជនសង្ស័យចំនួន០១នាក់(ស្រី០១នាក់) ជនរងគ្រោះចំនួន០២នាក់ អាយុពីក្រោមអាយុ១៨ឆ្នាំឡើង(ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ) ។

-ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ០១ករណី ជនសង្ស័យ ០១នាក់

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ:**

សរុបចំនួន០២ករណី/០៣ករណី ជនសង្ស័យចំនួន០២នាក់(ស្រី០១នាក់) ក្នុងនោះជនបរទេសចំនួន ០១នាក់(សញ្ជាតិហូឡង់) ជនរងគ្រោះចំនួន០៤នាក់ អាយុពី១៥-១៧ឆ្នាំចំនួន០២នាក់ អាយុ១៨ឆ្នាំឡើងចំនួន០២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៤នាក់) ។

-រូបភាព និងសម្ភារៈអាសអាភាស ០១ករណី ជនសង្ស័យ ០១នាក់ (សញ្ជាតិហូឡង់០១នាក់)

-សញ្ចារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) ០១ករណី ជនសង្ស័យ ០១នាក់

**៤. ការងារកិច្ចការយុត្តិធម៌**

តាមទិន្នន័យដែលបានទទួលពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោស នៅក្នុងខែមិថុនា ឆ្នាំ២០១៦នេះ តុលាការរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មិនទាន់បានបូកសរុបលទ្ធផលនៅឡើយ តែបានផ្តល់ទិន្នន័យសម្រាប់ឆមាសទី១ ឆ្នាំ២០១៦ ។

**៥. ការងារសហប្រតិបត្តិការអន្តរជាតិ**

+គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ្មាន)

+ក្រុមការងារការពារជនរងគ្រោះ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) បានចូលរួមកិច្ចប្រជុំទ្វេភាគី ស្តីពីការរៀបចំសេចក្តីព្រាងផែនការសកម្មភាព MOU រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលប់បំបាត់អំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ ។

+ក្រុមការងារអនុវត្តន៍ច្បាប់ (អគ្គស្នងការដ្ឋាននគរបាលជាតិ) បានធ្វើកិច្ចប្រជុំចំនួន០១លើក រវៀងនគរបាលកម្ពុជា និងនគរបាលប្រទេសវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការ ការបង្ក្រាបបទល្មើស និងសន្តិសុខសណ្តាប់ធ្នាប់តាមព្រំដែនរវាងប្រទេសទាំងពីរ ។

+ខេត្ត **ស្វាយរៀងស្នងការដ្ឋាននគរបាលខេត្ត** បានចូលរួមកិច្ចប្រជុំ និងសហប្រតិបត្តិរវាងនគរបាលខេត្តស្វាយរៀង (កម្ពុជា និងនគរបាលខេត្តឡុងអានប្រទេសវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកខុសច្បាប់ ស្វែងរកការងារធ្វើនៅក្រៅប្រទេសដែលពាក់ព័ន្ធនឹងអំពើជួញដូរ មនុស្សឆ្លងដែន បានចំនួន០១លើក មានអ្នកចូលរួមចំនួន៤៣នាក់ ស្រីចំនួន០២នាក់ នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្ត ។

+ខេត្ត **ប៉ៃលិន ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ** បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុន SOK-LEAP METREY CO.LTD ដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន០១លើក មានពលករចំនួន១៥នាក់ ស្រីចំនួន០៥នាក់ ។

### ៦. ការងារពាក់ព័ន្ធនឹងកុមារ

សកម្មភាពខិតខំប្រឹងប្រែង ក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារ ជាពិសេសកុមារងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មរបស់ គ.រ.ប.ជ/គ.ខ.ប.ជ សរុបបានចំនួន១០នាក់ ស្រីចំនួន០៩នាក់ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល បានទទួលកុមារីរងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទចំនួន០៩នាក់ ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ មកធ្វើការពិគ្រោះយោបល់ និងបានបញ្ជូនពួកគេឲ្យទៅទទួលសេវាថែទាំ ព្យាបាល និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន០៦ នាក់នៅអង្គការមេត្រីអន្តរជាតិ និងចំនួន០៣នាក់ទៀត នៅអង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ(CWCC) ភ្នំពេញ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ មន្ត្រីរបស់មន្ទីរសង្គមកិច្ច ០១នាក់ បានចុះទៅសម្ភាសដើម្បីកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងចំណោមនិរទេសជនដែលអជ្ញាធរថៃបានបញ្ជូនមករាល់ថ្ងៃ ត្រូវនឹងលក្ខណៈវិនិច្ឆ័យមានកុមារចំនួន០១នាក់ ជាជនងាយរងគ្រោះ ។

### ៧. ការងារទេសន្តរប្រវេសន៍

○ តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើការសម្ភាសពលករខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍បានចំនួន៨១គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលបានរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន១៣នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ព្រមទាំងបានសម្ភាសពលករ ពលការិនីរងគ្រោះចំនួន៨១នាក់ក្នុងនោះមាន ៖

-មកពីប្រទេសម៉ាឡេស៊ីចំនួន១០នាក់ ប្រទេសឥណ្ឌូនេស៊ីចំនួន៥៤នាក់ ប្រទេសចិនចំនួន០២នាក់ និងមកពីប្រទេសថៃ១៥នាក់(តាមការសម្ភាសទៅតាមក្រុមហ៊ុនចំនួន១០នាក់ តាមរយៈមេខ្យល់ចំនួន១៧នាក់ និង៥៤នាក់ទៀតទៅដោយខ្លួនឯង ។

តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែមិថុនាឆ្នាំ២០១៦ សរុបបានចំនួន**២៩៩,២៥៤**នាក់(ស្រីចំនួន**១៣០,២០២**នាក់) អនីតិជន មានចំនួន**៥,៨១៧**នាក់ (ស្រីចំនួន**២,២៦២**នាក់) ក្នុងនោះស្របច្បាប់ចំនួន**១៥៥,២៣០**នាក់(ស្រីចំនួន**៧០,៥០០**នាក់) និងអនីតិជនចំនួន**៦៤២**នាក់ (ស្រីចំនួន**២៦១**នាក់) មិនស្របច្បាប់ចំនួន**១៤៤,០២៤**នាក់ (ស្រីចំនួន**៥៩,៧០២**នាក់) និងអនីតិជនចំនួន**៥,១៧៥**នាក់(ស្រីចំនួន**២,០០១**នាក់) ។

## ខ.ការងារដឹកនាំសម្របសម្រួល

ការងារដឹកនាំសម្របសម្រួលសរុបរួមបានចំនួន៥៧លើក ក្នុងខែមិថុនា ឆ្នាំ២០១៦ ដែលធ្វើឡើងដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងគណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ។ (**ឧបសម្ព័ន្ធទី៧**)

**+សកម្មភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចំនួន១២លើក ៖**

- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ធ្វើការកែសម្រួលសេចក្តីព្រាង កិច្ចព្រមព្រៀងកម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ ។
- បានអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយបងប្អូនញាតិ មិត្តរបស់ពលករ ដែលកំពុងរង់ចាំពលករចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ និងកំពុងត្រូវបានជួយ សង្គ្រោះពីប្រទេសឥណ្ឌូនេស៊ី ហើយកំពុងបញ្ជូនត្រឡប់មកកាន់ស្រុកកំណើតវិញ មានចំនួន១៨នាក់ ពិធីប្រព្រឹត្តទៅនៅសាលាស្រុកជីក្រែង ខេត្តសៀមរាប ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសណ្ឋាគារអ៊ីមភើរៀល ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ។
- បានអញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីរដ្ឋបាល និងសមត្ថកិច្ចថ្នាក់ក្រោមជាតិចំនួន២ស្រុក ស្រុកពារាំង និងស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដើម្បីស្វែងយល់ពីស្ថានភាពប្រជាពលរដ្ឋដែលធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ។ ឆ្លៀតឱកាសនោះ លោកជំទាវបានអញ្ជើញជួបសួរសុខទុក្ខ និងពិនិត្យស្ថានភាព របស់បងប្អូនប្រជាពលរដ្ឋ ជាពលករចំណាកស្រុកដែលទើបបញ្ជូនត្រឡប់ពីប្រទេសឥណ្ឌូនេស៊ី មកកាន់ស្រុកកំណើតវិញ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ។
- បានអញ្ជើញជួបប្រជុំពិភាក្សាជាមួយតំណាងស្ថានទូតឥណ្ឌា ស្តីពីការរៀបចំអនុស្សរណៈ រវាងកម្ពុជា-ឥណ្ឌា ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃអគារទ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។
- បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហការ រវាងមន្ត្រីសង្គមកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសៀមរាបថោន ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦។
- បានទទួលជួបសំណេះសំណាលការងារជាមួយលោកស្រី Rebecca Black ប្រធានការងារបេសកកម្មប្រចាំកម្ពុជារបស់អង្គការ USAID ដោយលោកស្រីត្រូវបានបញ្ចប់អាណត្តិការងារនៅកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការដៃគូ ធ្វើការកែសម្រួលសេចក្តីព្រាងកិច្ចព្រមព្រៀង កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងពិភាក្សារៀបចំមេរៀនសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ។
- បានអញ្ជើញជាអធិបតីក្នុងការធ្វើបទបង្ហាញរបស់វិទ្យាស្ថានបើកទូលាយ ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីមូលហេតុ និងមធ្យោបាយក្នុងការធ្វើចំណាកស្រុកដើម្បីស្វែងរកការងាររបស់ពលករមានជំនាញទាប និងពលករគ្មានជំនាញក្នុងប្រទេសកម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ។

- បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំកម្មវិធីសម្រាប់កិច្ចប្រជុំ "ដកពិសោធន៍លើការងារគ្រប់គ្រងលំហូរមិនប្រក្រតីនៃពលករដែលឆ្លងកាត់ព្រំដែន" ដែលមានគម្រោងធ្វើនៅ ខេត្តបន្ទាយមានជ័យ នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ។
- បានទទួលជួបសំណេះសំណាលសំដែងការស្វាគមន៍លោក មៃខល ប្រ៊ូ មន្ត្រីផ្នែកនយោបាយរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា ដោយក្នុងជំនួបនោះលោក មៃខលប្រ៊ូ បានពាំនាំភាពសប្បាយរីករាយអបអរសាទរដែលសហរដ្ឋអាមេរិកបានដំឡើងចំណាត់ថ្នាក់កម្ពុជា ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពី "លេខ២កំពុងឃ្លាំមើល" មកកាន់ "លេខ២គ្មានការឃ្លាំមើល" ក្នុងឆ្នាំ២០១៦ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ។

## ឃ. ការលើកកម្ពស់សមត្ថភាព

### ១.ការបណ្តុះបណ្តាល

+**ក្រុមការងារអនុវត្តន៍ច្បាប់** បានសហការជាមួយអង្គការសន្តិសេនាបើកវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពទេសន្តរប្រវេសន៍ និងយន្តការឆ្លើយតបនឹងអំពើជួញដូរមនុស្ស ដែលមានសិក្ខាកាមចំនួន**៣០**នាក់ ស្រីចំនួន**០៧**នាក់ ។

+**ខេត្តសៀមរាប** ក្រុមការងាររបស់មន្ត្រីមន្ទីរសង្គមកិច្ចខេត្ត បានសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមណ្ឌល និងឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងសមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ។

+**ខេត្តបាត់ដំបង** លេខាធិការដ្ឋាន នៃគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមាននាយប៉ុស្តិ៍រដ្ឋបាលចូលរួមចំនួន **៧៥**នាក់ មកពីស្រុក (មោងឬស្សី រុក្ខគិរី គាស់ក្រឡ បាណន់ រតនមណ្ឌល ថ្មគោល បវេល សំពៅលូន ភ្នំព្រឹក កំរៀង និងស្រុសំឡូត) ។

+**ខេត្តស្វាយរៀង**

-ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការពារជួយជនរងគ្រោះក្រោយពេលធ្វើសមាហរណកម្ម និងការធ្វើចំណាកស្រុក នៅសាលា ស្រុកចន្ទ្រា ចំនួន០១វគ្គ មានអ្នកចូលរួមចំនួន**២២**នាក់ ស្រីចំនួន០៨នាក់ មានការឧបត្ថមគាំទ្រដោយអង្គការ MOI ។

+**ខេត្តកណ្តាល** មន្ទីរកិច្ចការនារីបានបើកវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រក្នុងការសម្របសម្រួលការបញ្ជ្រាបយេនឌ័រការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួមចំនួន**៣៧**នាក់ ស្រីចំនួន**៣៦**នាក់ ។

### ២. សិក្ខាសាលា

+**ខេត្តបាត់ដំបង** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ ១៩០ របស់រាជរដ្ឋាភិបាល និងប្រកាសបំពេញបន្ថែមចំនួន ០៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន បានចំនួន**០៥**ស្រុក (ស្រុកសង្កែ ស្រុកបាណន់ ស្រុកថ្មគោល ស្រុកឯកភ្នំ និងក្រុងបាត់ដំបង ) មានអ្នកចូលរួមសរុប**១២២**នាក់ ស្រីចំនួន**៣៨**នាក់ ។

## III. ការវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង ក្នុងខែមិថុនា ឆ្នាំ២០១៦នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី ភារកិច្ចរួម ជាស្រេច។

២. បានដាក់ចុះផែនការសកម្មភាពជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រាប់រយៈ ពេល៥ ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារទាំង៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ។

៤. បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

**ខ.ចំណុចសេសសល់ និងចាំណុចប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ក្រុមការងារអន្តរក្រសួងស្ថាប័ន ព្រមទាំងលេខាធិការដ្ឋានរាជធានី-ខេត្ត មួយចំនួនមិនទាន់បានផ្ញើរបាយការណ៍ប្រចាំខែ តាមការកំណត់ របស់ គ.ជ.ប.ជ នៅឡើយ ។
- ត្រូវពង្រឹងសមត្ថភាពដល់មន្ត្រីបំពេញការងារបន្ថែមទៀត ដោយមូលហេតុមានការផ្លាស់ប្តូរ សមាសភាព និងការរៀបចំជាថ្មីនូវរចនាសម្ព័ន្ធតាមបណ្តាថ្នាក់ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយ៉ាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ហើយចំណេះដឹងនិងការអប់រំ របស់ពួកគាត់នៅមានកម្រិតដូច្នេះទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ ។
- អង្គការជាតិ និងអន្តរជាតិមួយចំនួន នៅមិនទាន់ចូលរួមពេញលេញក្នុងការអនុវត្តយន្តការ និងសកម្មភាពរួមនេះហើយបានធ្វើសកម្មភាពដោយឡែក ដែលមិនឆ្លើយតបនឹងគោលដៅ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## IV.ទិសដៅសម្រាប់ខែកក្កដា ឆ្នាំ ២០១៦

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និង គោលការណ៍ណែនាំរបស់រាជ រដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍ ។

២. បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ ពាក់កណ្ដាលអាណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨ ។

៤. រៀបចំសកម្មភាពបណ្ដុះបណ្ដាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមបណ្ដាក្រសួង មន្ទីរ ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញការអនុវត្តបន្ត ។

៥. ត្រៀមសេចក្ដីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៦. ធ្វើការស្រាវជ្រាវ អំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុងនិងក្រៅប្រទេស និងស្វែងយល់ពីកត្តារុញច្រាន និងអូសទាញ ដើម្បីរៀបចំផែនការបង្ការទប់ស្កាត់ ។

៧. ត្រៀមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីពិនិត្យសម្រេចលើសេចក្ដីព្រាង កិច្ចព្រមព្រៀង ដែលបានឯកភាពគ្នាជាគោលការណ៍រួចហើយ កាលពីជំនួប នៅប្រទេសចិន នាខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ត្រៀមពិនិត្យ កិច្ចព្រមព្រៀង ទ្វេភាគី កម្ពុជា-ឥណ្ឌា តាមការស្នើសុំរបស់ រដ្ឋាភិបាលឥណ្ឌា ។

៩. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល(ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការដើម្បីចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និយោជក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ប្រកបដោយសមធម៌ ។

១០. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

១១. ជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ទៅតាមមុខសញ្ញានៃក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

១២. សម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែក គ្រប់វិស័យ និងរវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដើម្បីអនុវត្ត យុទ្ធសាស្ត្រ ដែលបានគ្រោងទុកក្នុងផែនការជាតិ ផែនការរបស់ក្រុមការងារទាំងប្រាំមួយ និងផែនការរាជធានី/ខេត្ត ។

១៣. គាំទ្រ និងពង្រឹងសមត្ថភាព របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

១៤. បន្តការងារផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការ យល់ដឹងជាសកល អំពីអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជ.-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យសម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ "ដើម្បីគោរពជូនជាសេចក្ដីរាយការណ៍"
- ឯកឧត្ដម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## ការងារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារ អនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលខេត្តកណ្តាល ,កំពង់ស្ពឺ ,រតនគិរី ,ស្វាយរៀង និងខេត្តឧត្តរមានជ័យ បានធ្វើការផ្សព្វផ្សាយស្តីពីច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ភូមិ/ឃុំ មានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 135 លើក | 8,611 នាក់ | 3,574 នាក់ |
| 2 | កោះកុង | ក្រុមការងារលេខាធិការដ្ឋាន គ ខ ប ជ ខេត្តបានធ្វើការប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការជួញដូរផ្លូវភេទ តាមរយៈការផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 8 លើក | 393 នាក់ | 325 នាក់ |
| 3 | ព្រះសីហនុ | ក្រុមការងារ គ.ខ.ប.ជ បានសហការជាមួយអាជ្ញាធរក្រុង/ស្រុក តាមរយៈការផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព និងអង្គការដៃគូរ ផ្សព្វផ្សាយអំពីការរំលោភបំពានផ្លូវភេទ បានធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការចំណាក់ស្រុកខុសច្បាប់ ជូនដល់ប្រជាពលរដ្ឋ កងកំលាំងប្រដាប់អាវុធ អាជ្ញធរភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត និងអង្គការសន្តិសេនា | 7 លើក | 1,446 នាក់ | 671 នាក់ |
| | | ក្រុមការងារបានចូលរួមផ្សព្វផ្សាយវេទិការសាធារណៈភូមិឃុំមានសុវត្ថភាព ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ /អ្នកគ្រូ និងប្រជាពលរដ្ឋ ។ | គណៈកម្មាធិការ គ.ខ.ប.ជ | 3 លើក | 252 នាក់ | 98 នាក់ |
| 4 | តាកែវ | ការិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃស្នងការនគរបាលខេត្តបានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ដល់ប្រជាពលរដ្ឋ នៅស្រុកព្រៃកប្បាស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 2 លើក | 64 នាក់ | 34 នាក់ |
| | | បានធ្វើវេទិកាពិគ្រោះយោបល់ ស្តីពីបញ្ហាប្រឈមក្នុងសង្គម ដែលមានផលប៉ះពាល់ដល់យុវវ័យ ក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅស្រុកអង្គរបូរី និងស្រុកព្រៃកប្បាស ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 2 លើក | 453 នាក់ | 278 នាក់ |
| 5 | កែប | ជូនដល់ប្រជាពលរដ្ឋ និងការផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សតាម រយៈវេទិការផ្សព្វផ្សាយស្តីពីគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ។ | គណៈកម្មាធិការ គ.ខ.ប.ជ | 12 លើក | 705 នាក់ | 372 នាក់ |
| | | បានធ្វើការផ្សព្វផ្សាយយល់ដឹងនូវច្បាប់ ស្តីពីការទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ។ | | 1 លើក | 150 នាក់ | 100 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | កណ្តាល | ក្រុមការងារថ្នាក់ស្រុកបានធ្វើការងារផ្សព្វផ្សាយអំពីការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាក់ស្រុកខុសច្បាប់ និងការចូលរួមរាយការណ៍ នូវចំណុចមិនប្រក្រតីរបស់ជនខិលខូច តាមភូមិ ។ | លេខាធិការដ្ឋានស្រុក និង អង្គការ W V C | 73 លើក | 7,284 នាក់ | 4,444 នាក់ |
| | | ក្រុមការងារថ្នាក់ស្រុកបាន បានសហការជាមួយអង្គការ W V C ក្នុងគម្រោង PADEE ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅក្នុងស្រុកទាំងមូល ។ | | 16 លើក | 904 នាក់ | 506 នាក់ |
| 7 | ស្វាយរៀង | បានចុះផ្សព្វផ្សាយវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស ការចំណាក់ស្រុកដោយសុវត្ថិភាព ជូនដល់ប្រជាពលរដ្ឋ លោកគ្រូនាក់គ្រូសិស្សានុសិស្ស | ស្នងការដ្ឋាននគរបាលខេត្ត | 179 លើក | 10,288 នាក់ | 5,327 នាក់ |
| 8 | ត្បូងឃ្មុំ | បានចុះផ្សព្វផ្សាយតាមវេទិការសាធារណៈ ស្តីពីការចំណាក់ស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋក្នុងស្រុកត្បូងឃ្មុំ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 6 លើក | 311 នាក់ | 186 នាក់ |
| 9 | ព្រះវិហារ | បានធ្វើការផ្សព្វផ្សាយបញ្ជ្រាបគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព ដល់មន្ត្រី រាជការ ប្រជាជន សិស្សានុសិស្ស បានចំនួន ៣២លើក លើ១៩ឃុំ ០២សង្កាត់ ០៧ស្រុក ០១ក្រុង | ស្នងការដ្ឋាននគរបាលខេត្ត | 32 លើក | 11,805 នាក់ | 6,181 នាក់ |
| | | បានធ្វើការផ្សព្វផ្សាយតាមរយៈវេទិការសាធារណៈស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស លើ១៣ឃុំ ០២សង្កាត់ ០៧ស្រុក ០១ក្រុង មានអាជ្ញាធរ មូលដ្ឋាន ប្រជាពលរដ្ឋ (ក្រុងព្រះវិហារ ស្រុករវៀង ស្រុកសង្គមថ្មី ស្រុកជ័យសែន ) ។ | ស្នងការដ្ឋាននគរបាលខេត្ត | 23 លើក | 10,640 នាក់ | 5,751 |
| 10 | កំពង់ធំ | ក្រុមការងារទី១ របស់លេខាធិការដ្ឋានបានផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សា និងអំពើជួញមនុស្ស នៅឃុំ ស្រើង និងឃុំឈូក និងភូមិបេង ភូមិដងអន្ទាក់ដែលមានមនុស្សចូលរួម | លេខាធិការដ្ឋានស្រុក | 2 លើក | 95 នាក់ | 42 នាក់ |
| 11 | កំពង់ឆ្នាំង | បានធ្វើការផ្សព្វផ្សាយលក្ខណៈសម្បត្ត ទាំង០៩ស្តីពីគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងសមត្ថកិច្ច ។ | គណៈកម្មាធិការ គ.ខ.ប.ជ | 288 លើក | 52,248 នាក់ | 3,694 នាក់ |
| | | បានធ្វើវេទិកាសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាព ដែលមានសមាសភាពចូលរួមមន្ត្រីរាជការ អង្គការសង្គមស៊ីវិល ,កងកម្លាំងប្រដាប់អាវុធ ,អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ ។ | | 359 លើក | 54,311 នាក់ | 30,941 |

| | | | | | | |
|---|---|---|---|---|---|---|
| 12 | សៀមរាប | បានចុះផ្សព្វផ្សាយអំពីច្បាប់ ស្ដីពីការបង្ក្រាបប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ដល់មន្ត្រីរាជការ ប្រជាពលរដ្ឋ និងអាជ្ញាធរក្រុង/ស្រុក ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរ-អង្គភាពពាក់ព័ន្ធ អាជ្ញា ធរក្រុង/ស្រុក និងអង្គការដៃគូ | 2 លើក | 310 នាក់ | 294 នាក់ |
| | | បានចុះផ្សព្វផ្សាយអំពីច្បាប់ ស្ដីពីការបង្ក្រាបប្រយុទ្ធប្រឆាំងអំពើជួញដូរកម្លាំងពលកម្ម អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកខុសច្បាប់ ដល់ក្រុមសន្សំ នៅឃុំកំពង់ឃ្លាំង ស្រុកសូទ្រ និគម និងបានជំរុញ និងតាមដានត្រួតពិនិត្យពលកម្មកុមារ នៅឃុំខ្នាសណ្ដាយ ស្រុកបន្ទាយ ស្រី និងស្រុកក្រឡាញ់ ។ | មន្ទីរការងារខេត្ត | 3 លើក | 41 នាក់ | 40 នាក់ |
| | | ការិយាល័យប្រឆាំងការជួញដូរមនុស្ស បានសហការជាមួយមន្ទីរអប់រំយុវជន និងកីឡា និងអង្គការ FCF រួមគ្នាពិគ្រោះយោបល់ជំរុញធ្វើការផ្សព្វផ្សាយអំពីច្បាប់ ស្ដីពីការបង្ក្រាបប្រយុទ្ធប្រឆាំងអំពើជួញដូរកម្លាំងពលកម្ម អំពើធ្វើអាជីវកម្មផ្លូវភេទ ដល់សិស្សវិទ្យាល័យអារញ្ញ និងវិទ្យាល័យ បាគង ។ | ស្នងការដ្ឋាននគរបាលខេត្ត មន្ទីរអប់រំយុវជន និងកីឡា និងអង្គការ FCF | 1 លើក | 600 នាក់ | 0 នាក់ |
| | | រដ្ឋបាលស្រុកជីក្រែង បានសហការជាមួយអង្គការការីតាស់ ធ្វើការផ្សព្វផ្សាយអំពីសវត្ថិភាពនៃការ ធ្វើចំណាកស្រុកដល់សហគមន៍ បានចំនួន០៤ភូមិ ។ | ស្រុកជីក្រែង និងអង្គការការីតាស់ | 1 លើក | 316 នាក់ | 269 នាក់ |
| 13 | ប៉ៃលិន | ក្រុមការងារលេខាធិការដ្ឋាន គ ខ ប ជ ខេត្តបានធ្វើការប្រជុំ ផ្សព្វផ្សាយច្បាប់ ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើទេសន្តរប្រវេសន៍ដល់ប្រជាពលរដ្ឋ សិស្សានុសិស្សវិទ្យាល័យ ទេពនិមិត្ត ហ៊ុន សែន និងវិទ្យាល័យសាលាក្រៅ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 2 លើក | 334 នាក់ | 128 នាក់ |
| 14 | បាត់ដំបង | បានធ្វើវេទិកាសាធារណៈ ស្ដីពីស្ដីពីគោលនយោបាយភូមិ /ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ កងកំលាំងប្រដាប់អាវុធ មន្ត្រីរាជការ ឲ្យគាត់យល់ដឹងអំពីការជួញដូរមនុស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 266 លើក | 53,240 នាក់ | 24,954 នាក់ |
| 15 | ពោធិ៍សាត់ | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈភូមិ/ឃុំមានសុវត្ថិភាព ក្រុងពោធិ៍សាត់, ស្រុកក្រគរ, កណ្ដៀង, ភ្នំក្រវាញ, បាកាន, វាលវែង, បានធ្វើការផ្សព្វផ្សាយ ស្ដីពីពលកម្មកុមារ ការរំលោភបំពានផ្លូវភេទ និងការធ្វើចំណាកស្រុកខុសច្បាប់ ដល់ប្រជាពលរដ្ឋ សិស្ស និងអាជ្ញាធរ ក្នុងក្រុង ស្រុក(សង្កាត់ ភូមិ ឃុំ) ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ អង្គការសម្រាលទុក្ខមនុស្សជាតិ និងអង្គការវឌ្ឍនភាព | 195 លើក | 25,922 នាក់ | 13,131 នាក់ |
| | | បានធ្វើវេទិកាសាធារណៈផ្សព្វផ្សាយច្បាប់ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈ ស្រុកក្រគរ ,ភ្នំក្រវាញ ,ស្រុកបាកាន និងបានសហការជាមួយអង្គការសម្រាលទុក្ខមនុស្សជាតិ និងអង្គការវឌ្ឍនភាព ។ | | 40 លើក | 6,897 នាក់ | 3,829 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 16 | ក្រចេះ | បានចុះផ្សព្វផ្សាយសកម្មភាពថ្នាក់ភូមិ ស្តីពីការទប់ស្កាត់ការជួញដូរស្ត្រីកុមារ ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការរំលោភសេពសន្ថវៈ ចំនួន០២ឃុំ ឃុំតាម៉ៅនិង ឃុំឆ្លូង ជូនដល់ប្រជាជន មន្ត្រីរាជការ កងកំលាំង មានសមត្ថកិច្ច ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 2 លើក | 96 នាក់ | 71 នាក់ |
| | | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចុះពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយសកម្មភាពថ្នាក់ក្រុង ស្រុក សង្កាត់ ភូមិ/ឃុំ មានក្រុងក្រចេះ ស្រុកចិត្របូរី និងស្រុកព្រែកប្រសព្វ ស្តីពីការទប់ស្កាត់ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព | | 1 លើក | 364 នាក់ | 72 នាក់ |

សកម្មភាពសរុបចំនួន: 1,661 លើក

មនុស្សសរុបចំនួន : 248,080 នាក់

ស្រីសរុបចំនួន : 105,312 នាក់

# តារាងឧបសម្ព័ន្ធទី៧
# ការងារដឹកនាំសម្របសម្រួល

| លរ. | អង្គភាព | សកម្មភាព | លើក | អ្នកពាក់ព័ន្ធ |
|---|---|---|---|---|
| ១ | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - បានអញ្ជើញជួបប្រជុំពិភាក្សាជាមួយតំណាងស្ថានទូតឥណ្ឌា ស្តីពីការរៀបចំអនុស្សរណៈរវាង កម្ពុជា-ឥណ្ឌា ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ អគារទ ថ្ងៃទី១៣ខែមិថុនា ឆ្នាំ២០១៦។<br>- បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្តីពីការពង្រឹងកិច្ច សហការរវាងមន្ត្រីសង្គមកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសៀមរាបថោន ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ។<br>- បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជារៀងរាល់ព្រឹកថ្ងៃច័ន្ទ ។<br>- បានចូលរួមសង្កេតការណ៍យកព័ត៌មានពីពលករនេសាទកម្ពុជាចំនួន២៧នាក់ ដែលត្រូវបានស្ថានទូតកម្ពុជា និងអាជ្ញាធរឥណ្ឌូនេស៊ីជួយអន្តរាគមន៍សង្គ្រោះពីទូកនេសាទថៃ បញ្ជូនមកកម្ពុជា ក្រោមការជួយឧបត្ថម្ភពី IOMឥណ្ឌូនេស៊ី នៅមណ្ឌលសំចតបណ្តោះអាសន្ន IOM កម្ពុជា ក្នុងសង្កាត់ព្រែកប្រា ខណ្ឌមានជ័យថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១៦ ។<br>- បានចូលរួមសង្កេតការណ៍ យកព័ត៌មានពីពលករនេសាទកម្ពុជាចំនួន ២៧នាក់ផ្សេងទៀត ដែលបានបញ្ជូនមកជាលើកទី២ ហើយបច្ចុប្បន្នពលករទាំង៥៤នាក់ត្រូវបានបញ្ជូនទៅកាន់ស្រុកកំណើតអស់ហើយ ក្នុងនោះមានខេត្តសៀមរាប ២១នាក់ ព្រៃវែង ១៩នាក់ កំពង់ស្ពឺ ៧នាក់ កោះកុង ២នាក់ កំពង់ចាម ១នាក់ តាកែវ ១នាក់ កំពង់ឆ្នាំង ១នាក់ និងខេត្តត្បូងឃ្មុំ ១នាក់ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ជួយ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅមណ្ឌល និងឧបករណ៍ត្រួត ពិនិត្យវាយតម្លៃការអនុវត្តគោលនយោបាយបទដ្ឋានអប្បបរមា នៅខេត្តសៀមរាប ថ្ងៃទី១៦-១៧ ខែមិថុនា ឆ្នាំ២០១៦ ។ | ០៦ លើក | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |

| | | | | |
|---|---|---|---|---|
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - បានធ្វើលិខិតចេញរបស់គណៈកម្មាធិការ គ.ជ.ប.ជ ចំនួន១៧ច្បាប់ និងលិខិតចូលចំនួន១២ច្បាប់ បានធ្វើលិខិតចេញចំនួន១៥ច្បាប់ និងលិខិតចូល១៥ច្បាប់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ខែជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំ ។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការ ដៃគូពាក់ព័ន្ធនានា ។<br>- ប្រមូលរបាយការណ៍ប្រចាំខែ និងឆមាសទី១ តាមបណ្តាអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥ និងបានបញ្ចប់បូកសរុបរបាយការណ៍ខែឧសភា ឆ្នាំ២០១៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បង្កើតទម្រង់បញ្ចេញ-បញ្ចូលឃ្លាំង សម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- រក្សាទុករូបភាព និងសកម្មភាពថ្នាក់ជាតិ និងក្រោមជាតិចូលក្នុងបណ្ណាសារ Wiki ។<br>- គ្រប់គ្រងទំព័រ facebook របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។<br>- ស្រាវជ្រាវព័ត៌មានពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន និង comment ផ្សេងៗ ពាក់ព័ន្ធនឹងអំពើជួញដូរ មនុស្សលើទំព័រ facebook ប្រមូលរបាយការណ៍តាមបណ្តារាជនី/ខេត្ត Telegram និង Gmail ។ | ៨លើក | លេខាធិការដ្ឋាន គ.ជ.ប.ជ |
| | | - បានពិនិត្យ និងតាមដានព័ត៌មានជាប្រចាំពីសកម្មភាពការបើកវេទិកាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមបណ្តារាជធានី-ខេត្ត តាមរយៈតេឡេក្រាម ។ | ០១ លើក | ក្រុមជំនួយកិច្ចការ បង្ការ ទប់ស្កាត់ |
| | | - ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ភាគីថៃបានបញ្ជូនសពពលរដ្ឋខ្មែរ ៦នាក់(ស្រី០២នាក់) និងគ្រោះថ្នាក់ដោយសារក្រឡាប់រថយន្ត(ស្រីចំនួន១១នាក់)របួស ០២នាក់មកឲ្យភាគីកម្ពុជា តាមច្រកអន្តរជាតិប៉ោយប៉ែត។<br>- បានចូលរួមជូនពលករដែលអាជ្ញាធរម៉ាឡេស៊ីបញ្ជូនមកកម្ពុជាវិញ ទៅដល់ស្រុកកំណើត ។<br>- បានស្រង់ទិន្នន័យពលករខ្មែរម្នាក់ដែលបានធ្លាក់ពីលើអគារកម្ពស់ជាន់ទី២០ស្លាប់ភ្លាមៗនៅប្រទេសថៃ។<br>- បានស្រង់ឈ្មោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលក្រសួងការបរទេសបញ្ជូនមកពីក្រៅប្រទេស ក្នុងខែមិថុនា ចំនួន ៣៦នាក់ ក្នុងនោះមកពីម៉ាឡេស៊ី ១០នាក់(ស្រី០២នាក់) ចិន០៤នាក់(ស្រី០៣នាក់) និងប្រទេសថៃចំនួន២២នាក់(ពលករចំនួន១៦នាក់ និងកុមារ០៦នាក់) ។ | ០៣ លើក | ក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ |
| | | | | |

| | | | | |
|---|---|---|---|---|
| | | - តាមដានសកម្មភាពការងារ ប្រមូលរបាយការណ៍ ពាក់ព័ន្ធនិងការងារអនុវត្តច្បាប់ នៅតាមបណ្តារាជធានី/ខេត្ត និងទំនាក់ទំនងសហការជាមួយក្រុមការងារអនុវត្តច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ។ | ០១ លើក | ក្រុមការងារអនុវត្តច្បាប់ |
| | | - បានចូលរួមប្រជុំពិភាក្សា ស្តីពីច្បាប់យុត្តិធម៌ដល់អនីតិជន នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីគំនិតផ្តួចផ្តើម បង្កើតផែនការយុទ្ធសាស្រ្ត ប្រព័ន្ធការពារកុមារជាតិ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ។ | ០២ លើក | ក្រុមជំនួយកិច្ចការយុត្តិធម៌ |
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | -បានជួយសម្រួលដល់ម្តាយនារីរងគ្រោះ ធ្វើពាក្យបណ្តឹងក្រុមហ៊ុន Dragon Cleaning ដែលបានបញ្ជូនកូនស្រីទៅធ្វើការជាអ្នកជូតសម្អាតតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ហើយត្រូវគេវាយធ្វើបាប(នារីរងគ្រោះបានទូរស័ព្ទប្រាប់ថាបច្ចុប្បន្ន គាត់ត្រូវបានស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីជួយអន្តរាគមន៍ និងឲ្យស្នាក់នៅក្នុងស្ថានទូតដើម្បីចាំដោះស្រាយប្រាក់ខែជាមួយនិយោជក ។<br>-បានបូកសរុបប្រចាំថ្ងៃនូវចំនួនពលករចំណាកស្រុកខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជាវិញ(ពីថ្ងៃទី ១-៣០ខែមិថុនា ឆ្នាំ២០១៦) សរុបចំនួន៣.១៨៧នាក់(ស្រីចំនួន៩៨៣នាក់ កុមារចំនួន៣១៧នាក់) ក្នុងនោះមាន៖<br>• តាមច្រកប៉ោយប៉ែតខេត្តបន្ទាយមានជ័យ មានចំនួន៣.០២៨នាក់(ស្រីចំនួន៩២៩នាក់កុមារចំនួន៣០៩នាក់)<br>• តាមច្រកសំពៅលូន ខេត្តបាត់ដំបង មានចំនួន១៥៩នាក់ (ស្រីចំនួន៥៤នាក់ កុមារចំនួន០៨នាក់) | ០២ លើក | ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ |
| ២ | បន្ទាយមានជ័យ | -បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយអង្គការដំណក់ទឹក អង្គការ CWCC និងអង្គការគ្រួសារថ្មី ស្តីពីការជួយស្រាវជ្រាវរក គ្រួសារជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៥នាក់ មុនពេលមាតុភូមិនិវត្តមកប្រទេសកំណើតវិញ។<br>-បានចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហការរវៀងមន្ត្រីសង្គមកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ស្នាក់នៅក្នុងមណ្ឌល និងឧបករណ៍ត្រួតពិនិត្យ វាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តសៀមរាប ។ | ២លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត និងមន្ទីរសង្គមកិច្ច |
| | ព្រះវិហារ | បានចាត់បញ្ជូនមន្ត្រីអនុវត្តច្បាប់ ចូលរួមវគ្គបណ្តុះបណ្តាល បំប៉នជំនាញ ស្តីពីច្បាប់សំខាន់ៗនៃក្រមនីតិវិធីព្រហ្ម | ១លើក | លេខាធិការដ្ឋាន |

| | | | | |
|---|---|---|---|---|
| | | ទណ្ឌ និងក្រមព្រហ្មទណ្ឌការប្រព្រឹត្តខុសត្រូវរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញការងារ ការរៀបចំឯកសារ និងពង្រឹងសំណុំរឿងទៅតុលាការ ។ | | គ.ខ.ប.ជ/ខេត្ត |
| ៣ | កំពង់ធំ | -ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស និងឆមាស ដើម្បីពិភាក្សាក្នុងក្រុមការងារទាំង ០៦ ដើម្បីស្វែងរកបញ្ហាប្រឈម និងរកដំណោះស្រាយ ។ | ១លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត |
| ៤ | សៀមរាប | -លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ.សរ ខេត្ត និងសមាជិកមកពីស្នងការនគរបាលខេត្ត មន្ទីរសង្គមកិច្ច មន្ទីរកិច្ចការនារី និងអង្គការដៃគូ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមស្តីពីសកម្មភាពទទួលពលករត្រឡប់មកពីប្រទេសឥណ្ឌូនេស៊ី បានចំនួន១៨នាក់(ប្រុស) នៅឃុំជីក្រែង ស្រុកជីក្រែង ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៦ ។<br>-ឯកឧត្តមអភិបាលខេត្ត ជាប្រធាន គ.ខ.ប.ជ. ខេត្ត លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ. ក្រោមអធិបតីភាព ឯកឧត្តម **អិត សំហេង** បានអញ្ជើញចូលរួមទិវាប្រយុទ្ធប្រឆាំងពលកម្មកុមារអន្តរជាតិ នៅស្រុកប្រសាទបាគង សូទ្រនិគម ជីក្រែង ក្រឡាញ់ និងស្រុកពួក ដែលមានប្រជាពលរដ្ឋ សិស្សានុសិស្ស ចូលរួមចំនួន**១៥៧៨** នាក់ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៦ ។<br>-លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ. ខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ស្នាក់នៅក្នុងមណ្ឌល និងឧបករណ៍ត្រួតពិនិត្យ វាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០១លើក នៅថ្ងៃទី១៦-១៧ ខែមិថុនា ឆ្នាំ២០១៦ ។<br>-ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ. ខេត្ត បានធ្វើការជូនដំណឹងដល់សមាជិក និងអង្គការដៃគូ ឲ្យធ្វើការផ្សព្វផ្សាយបន្ត អំពី សេចក្តីប្រកាសពត៌មាន របស់ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ ស្តីពីការជូនដំណឹងដល់បងប្អូនពលករដែលមានប័ណ្ណ ស្នាក់នៅបណ្តោះអាសន្នក្នុងប្រទេសថៃ (ប័ណ្ណស៊ីជំពូ) ដល់ពលរដ្ឋនៅតាមសហគមន៍ទូទាំង ១២ក្រុង/ស្រុក ។<br>-នាយកាវិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមកិច្ចប្រជុំ ស្តីពីការពង្រឹង សម្ថភាពមន្ត្រីតុលាការ និងនគរបាលយុត្តិធម៌ ក្នុងការអនុវត្តច្បាប់ទប់ស្កាត់ និងបង្រ្កាបបទល្មើសព្រហ្ម | ៦លើក | ប្រធានគណៈកម្មាធិការ និង លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត/ស្រុក |

| | | | | |
|---|---|---|---|---|
| | | ទណ្ឌនៅសាលាដំបូងខេត្តសៀមរាប ។<br>-រដ្ឋបាលស្រុកជីក្រែង បានសហការជាមួយអង្គការ MOI បើកវគ្គបណ្តុះបណ្តាលការគាំទ្រចិត្តសាស្ត្រសង្គម ដល់សហគមន៍ ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាពលករធ្វើចំណាកស្រុក និងការទប់ស្កាត់ភាពរងគ្រោះមុន និងក្រោយធ្វើទេសន្តរ ប្រវេសន៍ ដែលមានការបញ្ចាំងវីដេអូ ស្តីពីភាពរងគ្រោះដោយការធ្វើចំណាកស្រុកទៅក្រៅប្រទេស ជាពិសេសនៅលើទូកនេ សាទ ដែលមានអ្នកចូលរួមចំនួន៣០នាក់ ។ | | |
| ៥ | តាកែវ | -ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានជួបប្រជុំពិភាក្សាជាមួយប្រធានមន្ទីរកិច្ចការនារីខេត្ត បញ្ជូនប្រធានបទ"ប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស "ក្នុងវេទិកាពិគ្រោះយោបល់ ស្តីពីបញ្ហាប្រឈមក្នុងសង្គម និងផលប៉ះពាល់របស់យុវវ័យ ។ | ១លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/មន្ទីរកិច្ចការនារីខេត្ត |
| ៦ | កណ្តាល | -ក្រុមការងារថ្នាក់ស្រុក គ.ក.ស.ក បានប្រជុំប្រចាំខែ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ស្រុក ចំនួន០១លើក មានអ្នកចូលរួមចំនួន២៨នាក់ ស្រចំនួន១២នាក់ ។ | ១លើក | លេខាធិការដ្ឋាន គ.ក.ប.ក/ស្រុក |
| ៧ | ព្រៃវែង | -បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុក ដោយប្រថុយប្រថាន រៀបចំដោយក្រសួងកិច្ចការនារី ចំនួន០១លើក រយៈពេល០២ថ្ងៃ នៅសាលប្រជុំរបស់មន្ទីកិច្ចការនារី និងចំនួន០១លើកទៀត រយៈពេល០១ថ្ងៃ នៅស្រុកស៊ីធរកណ្តាល ។ | ១លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត/ស្រុក មន្ទីរកិច្ចការនារី |
| ៨ | ស្វាយរៀង | -ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ និងលើកទិសដៅបន្តឆមាសទី២ ឆ្នាំ២០១៦ មានអ្នកចូលរួមចំនួន៤០នាក់ ស្រីចំនួន២៣នាក់ មានការគាំទ្រដោយអង្គការសន្តិសេនា នៅសាលប្រជុំសាលាខេត្ត ។ | ១លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត និង អង្គការ |
| ៩ | ពោធិ៍សាត់ | -ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ស្រុកបានសហការជាមួយអង្គការវឌ្ឍនភាព បើកវគ្គបណ្តុះបណ្តាលស្តីពីពលកម្មកុមារ ប្រព័ន្ធតាមដានកុមារដល់អ្នកពាក់ព័ន្ធ និងអ្នកស្ម័គ្រចិត្តតាមភូមិចំនួន២១២នាក់ ស្រីចំនួន៩១នាក់ ។<br>-ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ស្រុកបានសហការជាមួយអង្គការវឌ្ឍនភាព និងអង្គការដៃគូផ្សេង | ២លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត និង អង្គការ |

| | | | | |
|---|---|---|---|---|
| | | ទៀត បាន ប្រារព្ធទិវាពិភពលោក ស្តីពីការប្រយុទ្ធប្រឆាំងពលកម្មកុមារ នៅក្នុងខេត្ត និងស្រុកក្រគរ ចំនួន០៤លើក មានអ្នកចូលរួមចំនួន៨,៨៦៣នាក់ ស្រីចំនួន៤,៤៦៦នាក់ | | |
| ១០ | **ត្បូងឃ្មុំ** | -ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានសហការជាមួយអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ ធ្វើការចុះស្រាវជ្រាវប្រមូលពត៌មានស្តីពីស្ត្រីរងគ្រោះ ដែលបានវិលត្រឡប់មកភូមិកំណើតវិញ។<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានធ្វើការប្រជុំផ្សព្វផ្សាយប្រចាំឆមាសទី១ និងការពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់មន្ត្រីជួរមុខរបស់គណៈកម្មាធិការ និងលេខាធិការដ្ឋាន គ.ខ.ប.ជ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ដែលមានការសហការជាមួយអង្គការ ស៊ីកាស្វា ។ | ២លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត និងអង្គការ |
| ១១ | **រតនគិរី** | -ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្សខេត្ត បានដឹកនាំប្រជុំរវាងក្រុមការងារជំនាញអន្តរមន្ទីរ ស្ថាប័នទាំង០៦ ស្តីពីការងារប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស នៅក្នុងខេត្ត ប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្ត ។<br>-មន្ទីរកិច្ចការនារី បានសហការជាមួយមន្ទីរកិច្ចការនារីខេត្ត បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីសកម្មភាព ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចនានា នៅខេត្តព្រៃវែង ដែលមានសិក្ខាកាមចូលរួមចំនួន៤៤នាក់ ស្រីចំនួន៣៨នាក់ មកពីមន្ទីរកិច្ចការនារីចំនួន០៨ខេត្ត/ក្រុង ។ | ២លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ/ខេត្ត និងមន្ទីរកិច្ចការនារីចំនួនខេត្ត/ក្រុង |
| ១២ | **ស្ទឹងត្រែង** | -មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចាត់មន្ត្រីជំនាញទទួលបន្ទុកការងារប្រឆាំងអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលបំប៉នសមត្ថភាព និងផ្សព្វផ្សាយប្រកាសលេខ១២៧៤ស.អ.យ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះស្នាក់នៅមជ្ឈមណ្ឌល និងប្រកាសលេខ២១៧៨ ស.អ.យ ស្តីពីការដាក់ឲ្យអនុវត្តឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃ នៅខេត្តសៀមរាប ។<br>-ការិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្ត បានចាត់មន្ត្រីជំនាញ០១រូបទៅចូលរួមសិក្ខាសាលា ស្តីពីវគ្គគ្រូបង្គោលប្រឆាំងការជួញដូរមនុស្ស រយៈពេល០៥ថ្ងៃ នៅអគ្គស្នងការនគរបាលជាតិ ។ | ២លើក | មន្ទីរសង្គមកិច្ច និងស្នងការដ្ឋាននគរបាលខេត្ត |

សកម្មភាពសរុបចំនួន ៤៥លើក